**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**លេខ : ០៤៤/២០០៣ កបធ.សជស**

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៣

## ជំរាបមក

**លោក ទី គីឡា**

អាស័យដ្ឋានផ្ទះលេខ ៥៤៧ ក្រុមទី ៤ ភូមិដំណាក់ធំ
សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

**កម្មវត្ថុ** : ប្ដឹងបដិសេធសេចក្ដីសម្រេចលេខ ០៥.៣២៤/០៣ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**យោង** : លិខិតរបស់លោក លេខ ពិសេស គ.ក.ខ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៣

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបលោកថា ក្រុម-ប្រឹក្សាធម្មនុញ្ញពុំអាចទទួលពាក្យបណ្ដឹងរបស់លោកយកមកពិនិត្យពិភាក្សាបានទេ ដោយករណីដែលលោកបានលើកឡើង មិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្រុមប្រឹក្សាធម្មនុញ្ញទទួលពិនិត្យបានតែករណីដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា៤២ ថ្មីនៃព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

រឿងជម្លោះរវាងលោក និង ឈ្មោះ ទី ឈមិន ជារឿងក្ដីរដ្ឋប្បវេណី ដែលស្ថិតនៅក្នុងសមត្ថកិច្ចតុលាការតែប៉ុណ្ណោះ ។

ប្រធាន

ប៊ិន ឈិន